## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ : ១២៧ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
## ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម/ ០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស /រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ខែធ្នូឆ្នាំ១៩៩៧ស្តីពីលក្ខន្តិកៈ គតិយុត្តិ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០១

# សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ ..**

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលសរសេរកាត់ថា " **ស.វ.ស.** " ត្រូវបានសំរេចអោយទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និង ស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ២ ..**

**ស.វ.ស.** ជានីតិបុគ្គល និង មានស្វ័យភាព ហិរញ្ញវត្ថុ ។ **ស.វ.ស.** មានអាសយដ្ឋានលេខ ៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ការផ្លាស់ប្តូរ អាសយដ្ឋាននៅពេលអនាគតជាសមត្ថកិច្ចរបស់ **ស.វ.ស.** ។

**មាត្រា ៣ ..**

**ស.វ.ស.** មានភារកិច្ចជាអាទិ៍ដូចតទៅ :

- បណ្តុះបណ្តាលអ្នកបច្ចេកទេសវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្ត-វេទនសាស្ត្រ និងថែទាំវេជ្ជសាស្ត្រថ្នាក់ឧត្តមគ្រប់កម្រិត និងធ្វើ វិក្រឹតការ អ្នកបច្ចេកទេស បង្កើនទាំងបរិមាណ និងគុណភាព ស្របតាមសំណូមពរនៃសេចក្តីត្រូវការទូទាំងព្រះរាជាណាចក្រកម្ពុជាតាមប្រព័ន្ធសាកលវិទ្យាល័យតាមរយៈការបង្រៀន ការរៀន និង ការបណ្តុះបណ្តាលមុខរបរវិជ្ជាជីវៈវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្ត-វេទនសាស្ត្រ វិទ្យាសាស្ត្រថែទាំ ព្រមទាំងបណ្តុះបណ្តាលបន្ត ដែលផ្តល់ជំនាញប្រកបដោយ គុណភាព វិញ្ញាបនបត្រ និងសញ្ញាប័ត្រ ព្រមទាំងរៀបចំ និង បើកសិក្ខាសាលា សន្និសីទផ្សេងៗ តាមសំណូមពរសង្គម
- បង្កើនសមត្ថភាពមុខជំនាញបច្ចេកទេសដល់គ្រូបង្រៀន សាស្ត្រាចារ្យសម្រាប់ មហាវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាលទាំង៣ និងសម្រាប់សាលាបច្ចេកទេស ថែទាំវេជ្ជសាស្ត្រ
- រៀបចំកម្មវិធីសិក្សាដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល
- **ស.វ.ស.** ផ្តល់និងរួមផ្តល់ ជាមួយគ្រឹះស្ថានបណ្តុះបណ្តាលដទៃទៀតនូវសញ្ញាប័ត្រកម្រិតជាតិ
- រៀបចំ ស្រាវជ្រាវវិទ្យាសាស្ត្រ វេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្ត-វេទនសាស្ត្រ និងវិទ្យាសាស្ត្រថែទាំ
- សិក្សាស្រាវជ្រាវកម្មវិធីសិក្សា ខ្លឹមសារសិក្សា វិធីសាស្ត្របង្រៀនចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រ ជាភាសាខ្មែរ និង ភាសាបរទេសឱ្យបានសមស្របសម្រាប់ប្រើប្រាស់ និងសម្រាប់ផ្សព្វផ្សាយទូទៅ

- រៀបចំនិងដំណើរការការងារប្រឡងជ្រើសរើស និស្សិត សិស្សឱ្យចូលរៀន ប្រឡងចេញ វាយតម្លៃការសិក្សាដោយខ្លួនឯងឱ្យបានត្រឹមត្រូវតាមគោលការណ៍ និង ប្រកបដោយតម្លាភាព

- កសាងផែនការមូលដ្ឋានសម្ភារៈសម្រាប់ **ស.ទ.ស.**

- ដើរតួជាសេនាធិការឱ្យរាជរដ្ឋាភិបាល ក្នុងការកសាងធនធានមនុស្ស លើវិស័យសុខាភិបាល

- គ្រប់គ្រងមន្ត្រីរាជការ និយោជិតកម្មករ និស្សិត សិស្ស សាស្ត្រាចារ្យ និង ទ្រព្យសម្បត្តិរបស់ **ស.ទ.ស.**

- ទំនាក់ទំនងសហប្រតិបត្តិការជាមួយអង្គការជាតិ-អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលនិងស្ថាប័ននានា ក្នុងគោលបំណងធ្វើឱ្យកាន់តែល្អប្រសើរ នូវការសិក្សាស្រាវជ្រាវ វិទ្យាសាស្ត្របច្ចេកទេស ។

## ជំពូកទី២

## រដ្ឋបាល និង ការគ្រប់គ្រង

### ផ្នែកទី១

### ក្រុមប្រឹក្សាភិបាល

**មាត្រា ៤ .-**

**ស.ទ.ស.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានសិទ្ធិយ៉ាងទូលំទូលាយ ដើម្បីចាត់ចែង ការងារក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និង បទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

**មាត្រា ៥ .-**

៥.១ -ក្រុមប្រឹក្សាភិបាលមានសមាជិក ០៧ រូប ដែលមានសមាសភាពដូចតទៅ :

- តំណាង ក្រសួងសុខាភិបាល ប្រធាន
- តំណាង ទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក
- តំណាងក្រសួងអប់រំ យុវជននិងកីឡា សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ជាសមាជិកស្វ័យប្រវត្តិ
- ឥស្សរជនដែលមានចំណេះដឹង និងបទពិសោធន៍ខាងវិទ្យាសាស្ត្រសុខាភិបាល ០១ រូប សមាជិក
- តំណាងបុគ្គលិក នៃសាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល ជាសមាជិកស្វ័យប្រវត្តិ

៥.២- តំណាងបុគ្គលិក នៃ សាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល ត្រូវជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោម បុគ្គលិក **ស.វ.ស.** ។

៥.៣ - ប្រធាន និងសមាជិកនៃក្រុមប្រឹក្សាដែលមិនមែនជាសមាជិកស្វ័យប្រវត្តិ ត្រូវបានតែងតាំងដោយអនុក្រឹត្យសម្រាប់ អាណត្តិ ៣ (បី) ឆ្នាំ រៀបចំដោយក្រសួងសុខាភិបាល តាមសំណើរបស់ក្រសួង ឬស្ថាប័នដែលខ្លួនតំណាងឱ្យ ។ អាណត្តិនេះអាចបញ្ចប់ បានគ្រប់ពេលវេលាដោយអនុក្រឹត្យ តាមសំណើនៃក្រសួង ឬ ស្ថាប័នដែលខ្លួនតំណាងឱ្យ។

**មាត្រា ៦ ៈ**

សមាជិកក្រុមប្រឹក្សាភិបាលត្រូវបានជ្រើសរើស ក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំរើការងារយ៉ាងតិច៥ (ប្រាំ) ឆ្នាំ ឬ ជាឥស្សរជនដែលមានអាយុមិនលើស ពី ៦៥ ឆ្នាំ និងមានបទពិសោធន៍គ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រសុខាភិបាល អប់រំ ឬ នីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្មកម្រិតធ្ងន់ពីតុលាការឡើយ ។

**មាត្រា ៧ ៈ**

៧.១.- ប្រធានក្រុមប្រឹក្សាភិបាលមានតួនាទី កោះប្រជុំ និងកំណត់របៀបវារៈ នៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។

៧.២.- ក្រុមប្រឹក្សាភិបាលអាចអញ្ជើញឥស្សរជននៅក្រៅក្រុមប្រឹក្សាភិបាល ដែលមានបទពិសោធន៍ លើវិស័យបណ្តុះ បណ្តាលវិទ្យាសាស្ត្រសុខាភិបាល និងតំណាងអ្នកផ្តល់ជំនួយចូលរួមក្នុងអង្គប្រជុំ របស់ក្រុមប្រឹក្សាភិបាល ។ ឥស្សរជនទាំងនេះ មានសិទ្ធិ ផ្តល់មតិ តែពុំមានសិទ្ធិបោះឆ្នោត អនុម័តឡើយ ។

**មាត្រា ៨ ៈ**

ក្រុមប្រឹក្សាភិបាលមានបេសកម្មដឹកនាំ តំរង់ទិសដៅ និងធ្វើការត្រួតពិនិត្យ លើដំណើការរបស់សាកលវិទ្យាល័យ។ ក្នុងក្របខ័ណ្ឌ នៃបេសកម្មនេះ ក្រុមប្រឹក្សាភិបាលត្រូវ :

- ពិនិត្យ និងសម្រេចលើគំរោងផែនការអភិវឌ្ឍ នៃ **ស.វ.ស.** ស្របតាមទិសដៅកំណត់របស់រាជរដ្ឋាភិបាល
- ពិនិត្យ និងសម្រេចលើចំណូល និងចំណាយជាប្រចាំព្រមទាំងទុន ក្នុងថវិកាប្រចាំឆ្នាំរបស់ **ស.វ.ស.**
- ពិនិត្យ និងសម្រេចលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ការរៀបចំរចនាសម្ព័ន្ធ ព្រមទាំងការបែងចែកភារកិច្ចជាទូទៅដល់អង្គភាពក្រោមឱវាទ
- កំណត់ទូវរបបជ្រើសរើស ការតម្លើងឋានន្តរសក្តិ ការផ្តល់លាភការ ដល់បុគ្គលិក **ស.វ.ស.** ដោយមិនប៉ះពាល់ដល់ បទប្បញ្ញត្តិច្បាប់ ឬ បទបញ្ជាផ្ទៃក្នុងដែលអនុវត្តចំពោះភ្នាក់ងារមុខងារសាធារណៈ
- សម្រេចលើក្របខ័ណ្ឌចំនួនបុគ្គលិក ដែលអនុញ្ញាតសម្រាប់ **ស.វ.ស.**
- សម្រេចលើកិច្ចសន្យា ស្តីពីលទ្ធកម្ម

- កំណត់បទបញ្ជាផ្ទៃក្នុងនៃ **ស.ថ.ស.**

- ធ្វើការវាយតម្លៃតាមចន្លោះពេលទៀងទាត់ លើកម្រិតលទ្ធផលសម្រេចបាន តាមគោលដៅកំណត់ដោយ **ស.ថ.ស.** ហើយកំណត់នូវវិធានការកែតម្រូវដើម្បីអនុវត្ត ។

**មាត្រា ៩ .-**

លាភការរបស់សមាជិកក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់របស់សាកលវិទ្យាធិការ ត្រូវកំណត់ដោយរដ្ឋមន្ត្រី ក្រសួងសុខាភិបាល និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាក្រុមប្រឹក្សាភិបាល ។

**មាត្រា ១០ .-**

១០.១.- ក្រុមប្រឹក្សាភិបាល នៃ **ស.ថ.ស.** ត្រូវធ្វើការប្រជុំយ៉ាងតិចមួយត្រីមាសម្តង តាមការអញ្ជើញរបស់ប្រធាន ឬ តាមការស្នើរបស់សមាជិកចំនួន ២/៣ ( ពីរភាគបី ) ឡើងទៅ ឬ តាមការស្នើសុំពីសាកលវិទ្យាធិការ នៃ **ស.ថ.ស.** ។ ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់ដែលមានវ័យច្រើនជាងគេ ក្នុងចំណោមសមាជិករបស់ក្រុមប្រឹក្សាភិបាលវត្តមាន ដើម្បីដឹកនាំការប្រជុំ ។ ប្រធានអង្គប្រជុំ ត្រូវជ្រើសរើសលេខាធិការនៃអង្គប្រជុំ១ (មួយ)រូប ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាល។ លេខាធិការនេះគ្មានសិទ្ធិបោះឆ្នោតទេ ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលមានចែងក្នុងអនុក្រឹត្យនេះ ត្រូវចូលរួមប្រជុំក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែគ្មានសិទ្ធិបោះឆ្នោតទេ ។ របៀបវារៈព្រមទាំងឯកសារទាំងឡាយត្រូវ ផ្ញើជូនគ្រប់សមាជិកនៃក្រុមប្រឹក្សាភិបាល និង គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានចែងក្នុងអនុក្រឹត្យនេះយ៉ាងតិច **១០(ដប់)** ថ្ងៃ មុនថ្ងៃប្រជុំ ។

១០.២.- ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចនឹងយកជាការបាន លុះត្រាតែមានសមាជិកវត្តមានចំនួនលើសពី ៥០(ហាសិប) ភាគរយ នៃសមាជិកទាំងអស់ ។ សមាជិកអវត្តមានគ្មាន សិទ្ធិបញ្ជូនតំណាងឱ្យមកប្រជុំជំនួសខ្លួនបានឡើយ ។ បើសិនសំឡេងកូរ៉ុមមិនគ្រប់ចំនួនទេ ក្រុមប្រឹក្សាភិបាល ត្រូវកោះប្រជុំម្តងទៀតយ៉ាងយូរ **១៥ (ដប់ប្រាំ)** ថ្ងៃ ក្រោយថ្ងៃប្រជុំលើកមុន ហើយការប្រជុំលើកក្រោយនេះ មិនចាំបាច់តំរូវឱ្យមានគ្រប់កូរ៉ុមឡើយ ហើយត្រូវ ពិភាក្សាតែលើរបៀបវារៈ នៃការអញ្ជើញប្រជុំលើកទីមួយ ។ សមាជិកវត្តមានត្រូវចុះហត្ថលេខាលើបញ្ជីវត្តមានមួយ ។ សេចក្តីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័ត ដោយសម្លេងភាគច្រើន នៃសមាជិកវត្តមាន ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានអង្គប្រជុំ ចាត់ទុកជាឧត្តមានុភាព។

១០.៣.-សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដកល់ទុក នៅទីស្នាក់ការរបស់ **ស.ថ.ស.** និងត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និង លេខាធិការអង្គប្រជុំ ។ កំណត់ហេតុនេះត្រូវបង្ហាញ នូវអត្ថន័យនៃការពិភាក្សាឱ្យបានច្បាស់លាស់ និង ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងផ្ញើជូនក្រសួងពាក់ពន្ធ័យ៉ាងយូរ ១០ (ដប់) ថ្ងៃ ក្រោយពេលប្រជុំ។

១០.៤.-**ស.ថ.ស.** ត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នូវឯកសារដូចតទៅ :

- កំណត់ហេតុ នៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល

- កំណត់ហេតុ នៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍរបស់សាកលវិទ្យាល័យ
- ថវិកាប្រចាំឆ្នាំ
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

១០.៥.- ឯកសារទាំងនេះ ត្រូវបញ្ជូនទៅអ្នកដែលត្រូវទទួលក្នុងរយៈពេលមិនឱ្យហួសពី ១៥ (ដប់ប្រាំ) ថ្ងៃ ។

# ផ្នែកទី ២

## អង្គការប្រតិបត្តិរបស់សាកលវិទ្យាល័យ

**មាត្រា ១១ .-**

**ស.វ.ស.** ត្រូវគ្រប់គ្រងដោយសាកលវិទ្យាធិការមួយរូប ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ដោយមានការផ្តល់យោបល់ពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។ សាកលវិទ្យាធិការនេះមានតួនាទីជានាយកប្រតិបត្តិ ។

**មាត្រា ១២ .-**

១២.១ - សាកលវិទ្យាធិការនៃ **ស.វ.ស.** មានសិទ្ធិពេញលេញ ដើម្បីគ្រប់គ្រងនិងអនុវត្តការងារ ដែលមានចែងក្នុងច្បាប់ និង អនុក្រឹត្យនេះ លើកលែងតែកិច្ចការដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាភិបាល។

សាកលវិទ្យាធិការមានភារកិច្ច :

- រៀបចំការងារអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកអនុវត្តសេចក្តីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាល ព្រមទាំងដាក់ឱ្យដំណើរការ នូវ នយោបាយដែលកំណត់ដោយក្រុមប្រឹក្សានេះ
- រៀបចំថវិកាប្រចាំឆ្នាំសម្រាប់ **ស.វ.ស.** ហើយដាក់ជូនក្រុមប្រឹក្សាភិបាល ពិនិត្យសម្រេច
- ធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និង រាល់សកម្មភាព ផ្សេងៗទៀត ហើយដាក់ឯកសារទាំងនេះជូនក្រុមប្រឹក្សាភិបាលពិនិត្យសម្រេច
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ លើភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- បំពេញរាល់មុខតំណែងរបស់ **ស.វ.ស.** ក្នុងការកម្រិតក្របខ័ណ្ឌចំនួនបុគ្គលិក ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ព្រមទាំងគោរពតាមវិធានស្តីពីការគ្រប់គ្រងបុគ្គលិក
- បំពេញតួនាទី តាមឋានានុក្រម ចំពោះបុគ្គលិកទាំងមូលរបស់ **ស.វ.ស.**

ក្រុមប្រឹក្សាភិបាល ស្តីពីការបែងចែកសិទ្ធអំណាច និងទៅតាមបទបញ្ជាផ្ទៃក្នុង ព្រមទាំងបទប្បញ្ញត្តិ ដទៃទៀតស្តីពីបញ្ហានេះ

ជារូមតីបំពេញរាល់មុខងាររដ្ឋបាល និងគ្រប់គ្រងការងារទាំងឡាយដែលត្រូវបានប្រគល់ឱ្យ តាមបទបញ្ជាផ្ទៃក្នុង របស់**ស.ទ.ស.** និង តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

១២.២- សាកលវិទ្យាធិការ នៃ **ស.ទ.ស.** ជាតំណាងរបស់សាកលវិទ្យាល័យ ក្នុងការទំនាក់ទំនងជាមួយ តតិយជន ។

១២.៣- សាកលវិទ្យាធិការ នៃ **ស.ទ.ស.** ត្រូវស្នើទៅក្រុមប្រឹក្សាភិបាល សុំតែងតាំងសាកលវិទ្យាធិការរងមួយរូប ឬ ពីររូប មានឋានៈស្មើប្រធាន នាយកដ្ឋាន ជាជំនួយការតាមការចាំបាច់ ។

## ផ្នែកទី៣

## បុគ្គលិករបស់ "ស.ទ.ស."

**មាត្រា ១៣ .-**

១៣.១- បុគ្គលិកអចិន្ត្រៃយ៍របស់ **ស.ទ.ស.** រួមមានមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈមកពីក្រសួងសុខាភិបាល ឬ ជ្រើសរើសតាមសំណើរបស់សាកលវិទ្យាធិការ នៃ **ស.ទ.ស.** ។ មន្ត្រីទាំងនេះត្រូវបានរក្សាទុកនូវក្របខ័ណ្ឌប្រាក់បៀវត្ស និង ប្រាក់កម្រៃផ្សេងៗ ដែលបានកំណត់ដោយមុខងារសាធារណៈពីអង្គភាពដើមរបស់ខ្លួន ។

១៣.២- សាកលវិទ្យាល័យ អាចជ្រើសរើសភ្នាក់ងារជាប់កិច្ចសន្យាជំនួយការនិងបុគ្គលិកអណ្តែត ។ ភ្នាក់ងារទាំងនេះ ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃបទបញ្ជាផ្ទៃក្នុង និង តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់ ស្តីពីការងារ ។

១៣.៣- បុគ្គលិក **ស.ទ.ស.** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង នៃបទបញ្ជាស្តីពីបុគ្គលិកសម្រេចដោយក្រុមប្រឹក្សាភិបាល ។ ក្រុមប្រឹក្សាភិបាលកំណត់ប្រាក់កំរៃលើកទឹកចិត្ត ចំពោះបុគ្គលិកព្រមទាំងបែបបទ នៃការទូទាត់ផងដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង ។

## ផ្នែកទី ៤

## ទ្រព្យសម្បត្តិរបស់ " ស.ទ.ស. "

**មាត្រា ១៤ .-**

១៤.១- **ស.ទ.ស.** ទទួលដើមទុនដំបូងពីរដ្ឋនូវអចលនវត្ថុដូចតទៅ :

- ដីជាទីតាំងនៃសាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាលមានសមាសភាគផ្ទៃក្នុង ៤ ដែលមានឈ្មោះដូចតទៅ

- មហាវិទ្យាល័យវេជ្ជសាស្ត្រ
- មហាវិទ្យាល័យឱសថសាស្ត្រ
- មហាវិទ្យាល័យទន្ត-វេទនសាស្ត្រ
- សាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ

មានផ្ទៃដី ១៦៧៤៥ម² ស្ថិតនៅសង្កាត់ ស្រះចក ខណ្ឌ ដូនពេញ និង មានផ្ទៃដី ១១៦៦៧ ម²៨០ ស្ថិតនៅ សង្កាត់ទំនប់ទឹក ខណ្ឌ ចំការមន រាជធានីភ្នំពេញ ។

១៤.២- ក្រៅពីអចលនទ្រព្យខាងលើ **ស.វ.ស.** ត្រូវបានទទួលនូវចលនទ្រព្យ និងអចលនទ្រព្យផ្សេងៗដែលកំពុងប្រើប្រាស់ពេលបច្ចុប្បន្ន ។

១៤.៣- អចលនទ្រព្យ និង ចលនទ្រព្យទាំងអស់ របស់ **ស.វ.ស.** មានចែងលម្អិតក្នុងបញ្ជីសារពើភណ្ឌដូចមាន ឧបសម្ព័ន្ធខាងក្រោយ ។

១៤.៤- **ស.វ.ស.** អាចទិញ លក់ចលនទ្រព្យ និង ទិញអចលនទ្រព្យចាំបាច់សម្រាប់ដំណើរការរបស់ខ្លួន ។

## ផ្នែកទី ៥

## ការគ្រប់គ្រងហិរញ្ញវត្ថុ និង គណនេយ្យរបស់ "ស.វ.ស."

**មាត្រា ១៥.-**

ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យនៃ ស.វ.ស. ត្រូវប្រព្រឹត្តស្របតាមគោលការណ៍ នៃគណនេយ្យសាធារណៈ ដូចមានចែងក្នុងមាត្រា ១២២ នៃអនុក្រឹត្យលេខ ៨២ អនក្រ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្ដីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។

**មាត្រា ១៦ .-**

១៦.១- សាកលវិទ្យាធិការនៃ **ស.វ.ស.** ជាអាណាប័កដើមខ្សែរបស់សាកលវិទ្យាល័យ ហើយត្រូវមានភារកិច្ច :

- ពិនិត្យប្រាក់ និងទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ

១៦.២-អាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិ ឱ្យអាណាប័កផ្ទេរសិទ្ធិឬអាចបង្កើតនូវវរជ្ជទេយ្យចំណូល ឬ បុរេប្រទានបាន ដោយមានការព្រមព្រៀងពីភ្នាក់ងារគណនេយ្យ ។

**មាត្រា ១៧ ._**

១៧.១- ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ **ស.ទ.ស.** ក្រោមការទទួលខុសត្រូវផ្ទាល់របស់ភ្នាក់ងារគណនេយ្យ ។ ភ្នាក់ងារគណនេយ្យនេះត្រូវតែងតាំង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយត្រូវសច្ចាប្រណិធានមុនចូលកាន់ការងារ ។ភ្នាក់ងារគណនេយ្យនេះត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នកពិគ្រោះយោបល់ តែឥតមានសម្លេងឆ្នោតឡើយ ។

១៧.២ - ភ្នាក់ងារគណនេយ្យមានភារកិច្ច :

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ
- រក្សាទុក និងចាត់ចែងប្រើប្រាស់នូវមូលនិធិ និងធនធានរបស់សកលវិទ្យាល័យ
- រក្សាទុកនូវលិខិតយុត្តិការ និង កានកាប់បញ្ជីគណនេយ្យ ។

១៧.៣- ភ្នាក់ងារគណនេយ្យ អាចផ្ទេរសិទ្ធិខ្លះទៅឱ្យអាណាព្យាបាលរបស់ខ្លួន ។

**មាត្រា ១៨ ._**

១៨.១- ប្រភពធនធានរបស់ **ស.ទ.ស.** រួមមាន :

- ធនធានដំបូងដែលរដ្ឋផ្តល់ដល់ **ស.ទ.ស.** នៅពេលផ្តើមបង្កើតដំបូង
- ឧបត្ថម្ភធនសម្រាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធន ដែលមានចែងក្នុងថវិការដ្ឋ
- អំណោយ ជំនួយ និង អច្ច័យទានដែល **ស.ទ.ស.** បានទទួល
- ប្រាក់ខ្ចីបុលដោយសាកលវិទ្យាល័យផ្ទាល់ និងប្រាក់ដែលរដ្ឋខ្ចីបុលឱ្យ **ស.ទ.ស.**
- ផលការងារ និងកំរៃនៃការផ្តល់សេវាផ្សេងៗដោយ **ស.ទ.ស.**
- កម្រៃនៃទ្រព្យសម្បត្តិរបស់ **ស.ទ.ស.** និង ចំណូលនៃការលក់ទ្រព្យសម្បត្តិដែលបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល
- កម្រៃនៃទ្រព្យសម្បត្តិដែលបានប្រគល់ឱ្យ **ស.ទ.ស.** ។

១៨.២-ចំណូលចំណាយជាប្រចាំព្រមទាំងមូលធនរបស់ **ស.ទ.ស.** ត្រូវបានគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់សាកលវិទ្យាល័យ ។ ក្រុមប្រឹក្សាភិបាលរបស់ **ស.ទ.ស.** ត្រូវចែងអំពីបែបបទនៃការរៀបចំការចាត់ចែងនិងអនុវត្តថវិកា ។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលទាក់ទងដល់ទំរង់បែបបទ នៃការរៀបចំការចាត់ចែងនិងអនុវត្តថវិកា ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

១៨.៣-ថវិកាត្រូវរៀបចំដោយអាណាប័កដើមខ្សែ **ស.ទ.ស.** ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល ដែលត្រូវធ្វើការសម្រេច

យ៉ាងយូរត្រឹមថ្ងៃទី ៣០ ខែ កញ្ញា ក្នុងឆ្នាំនីមួយៗ។ ថវិកាត្រូវតែធ្វើឱ្យមានលំនឹងរវាងចំណូល និងចំណាយ ។

**មាត្រា ១៩ .-**

១៩. ១- ការងារគណនេយ្យរបស់ **ស.ទ.ស.** រួមមាន :

- គណនេយ្យទូទៅត្រូវកាន់កាប់ជាគណនេយ្យទ្វេភាគដែលចែងអំពីប្រត្តិបត្តិការថវិកា រតនាគារ និងប្រតិបត្តិការដែលអនុវត្តជាមួយតតិយជន
- គណនេយ្យ អសង្ហារឹម រូបធាតុ និង គណនេយ្យតម្លៃ
- គណនេយ្យវិភាគ ប្រសិនបើជាការចាំបាច់

គណនេយ្យរបស់សាកលវិទ្យាល័យត្រូវ :

១- ស្របតាមវិធានដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២- គោរពតាមប្លង់គណនេយ្យរបស់ **ស.ទ.ស.**ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល ។ ប្លង់គណនេយ្យនេះត្រូវបានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

១៩.២- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់សាកលវិទ្យាល័យ ត្រូវរៀបចំដោយភ្នាក់ងារគណនេយ្យនិងអាណាប័កដើមខ្សែដោយភ្ជាប់ជាមួយរបាយការណ៍គ្រប់គ្រង ដើម្បីជូនក្រុមប្រឹក្សាភិបាលពិនិត្យ និង សម្រេចលើឯកសារទាំងនោះយ៉ាងយូរ ៣(បី)ខែ ក្រោយការបិទការិយបរិច្ឆេទគណនេយ្យ ។

**មាត្រា ២០ .-**

មូលនិធិរបស់ **ស.ទ.ស.**គឺជាមូលនិធិសាធារណៈដែលត្រូវដាក់ចូលក្នុងគណនីមួយនៅរតនាគារជាចាំបាច់ លើកលែងតែមានបដិបញ្ញត្តិដែលត្រូវមានការយល់ព្រមតាមប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ផ្នែកទី ៦

## របបសារពើពន្ធនៃ " ស.ទ.ស."

**មាត្រា ២១ .-**

លើកលែងតែមានបដិបញ្ញត្តិដែលចែងដោយច្បាប់ **ស.ទ.ស.** ត្រូវស្ថិតនៅក្រោមនីតិរបបចំពោះរបបសារពើពន្ធដូចដែលត្រូវបានអនុវត្តលើអង្គភាពនានារបស់រដ្ឋ ។



៤ሂ

## ផ្នែកទី ៧

## លទ្ធកម្មរបស់ " ស.ទ.ស."

**មាត្រា ២២ .-**

ការសម្រេច ការអនុវត្ត និង ការត្រួតពិនិត្យ លើលទ្ធកម្មរបស់ **ស.ទ.ស.** ត្រូវគ្រប់គ្រងតាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ៦០ អនក្រ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីលទ្ធកម្មសាធារណៈ និងបទបញ្ជាដទៃទៀតពាក់ព័ន្ធ នឹងបញ្ហានេះ ។

## ជំពូកទី ៣

## ផ្នែកទី ១

## អាណាព្យាបាលបច្ចេកទេស

**មាត្រា ២៣ .-**

២៣.១- ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពីការប្រជុំក្រុមប្រឹក្សាភិបាល សាកលវិទ្យាធិការ នៃ **ស.ទ.ស.** ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវកម្មវិធីអភិវឌ្ឍ និងគម្រោងថវិកាប្រចាំឆ្នាំដើម្បីសុំការយល់ព្រម ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល ១ (មួយ) ខែ ចាប់ពីថ្ងៃដែលបានទទួលឯកសារ ត្រូវរៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។ រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេសមាន ២ (ពីរ)ខែ គិតចាប់ពីថ្ងៃដែលបានទទួលឯកសារដែលបញ្ជូនដោយសាកលវិទ្យាធិការ ដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនេះ ។

២៣.២- លិខិតយល់ព្រមត្រូវចុះហត្ថលេខា ដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬតំណាង ហើយត្រូវផ្ញើជូនទៅសាកលវិទ្យាធិការនៃ **ស.ទ.ស.** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ សាកលវិទ្យាធិការនៃ **ស.ទ.ស.** ត្រូវបញ្ជូនពត៌មាននេះទៅឱ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសុខាភិបាល មិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះកម្មវិធីអភិវឌ្ឍ ឬ គម្រោងថវិកាប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព ។ ប្រសិនបើរដ្ឋមន្ត្រីក្រសួងសុខាភិបាល ធ្វើការជំទាស់លើកម្មវិធី អភិវឌ្ឍ ឬគម្រោង

ថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ ដើម្បីពិភាក្សា និងរិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់ទាំងនេះ ។

កម្មវិធីអភិវឌ្ឍនៃ **ស.ទ.ស.** និង ថវិកាចំណាយជាមូលធនមិនអាចឱ្យអនុវត្តបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយប្រធានស្ថាប័ន ឬអាណាព្យាបាលបច្ចេកទេស ។

ថវិកាចំណាយជាប្រចាំអាចដាក់ឱ្យអនុវត្តត្រឹមលំនាំបំបែកជា ១២ (ដប់ពីរ) ប៉ុណ្ណោះ នៅពេលដែលមានការជំទាស់ពីប្រធានស្ថាប័ន ឬ អាណាព្យាបាលបច្ចេកទេស ។

**មាត្រា ២៤ .-**

២៤.១- រដ្ឋមន្ត្រីក្រសួងសុខាភិបាល អាចមានយោបល់ជំទាស់លើឯកសារ ដែលបានត្រូវបញ្ជូនមកខ្លួនដូចមានចែងក្នុងមាត្រា២៣ ខាងលើមាន : កំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ។ រដ្ឋមន្ត្រីក្រសួងសុខាភិបាលមានរយៈពេល ១ (មួយ) ខែ សម្រាប់លើកឡើងនូវការជំទាស់ទាំងអស់នេះ ។

២៤.២- សាកលវិទ្យាធិការនៃ **ស.ទ.ស.** ត្រូវជូនពត៌មានទៅដល់ក្រុមប្រឹក្សាភិបាល នូវខ្លឹមសារនៃការជំទាស់របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។ ក្រុមប្រឹក្សាភិបាល ត្រូវធ្វើការពិភាក្សាឱ្យបានឆាប់បំផុត លើការជំទាស់របស់រដ្ឋមន្ត្រី ក្រសួងសុខាភិបាល និងរិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់ទាំងនេះ ។ ប្រសិនបើក្រុមប្រឹក្សាភិបាល សម្រេចពុំយកជាបានការ នូវការជំទាស់ទាំងនេះ សេចក្តីសម្រេចក្រុមប្រឹក្សាភិបាលត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវរាយការណ៍ជូនដំណឹងជាបន្ទាន់ភ្លាម ស្តីពីបញ្ហានេះជាលាយលក្ខណ៍អក្សរដល់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា ២៥ .-**

២៥.១ - រដ្ឋមន្ត្រីក្រសួងសុខាភិបាល អាចលុប ឬផ្អាកទុកនូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬសាកលវិទ្យាធិការនៃ **ស.ទ.ស.** ក្នុងករណីដែលសេចក្តីសម្រេចនោះ :

- ផ្ទុយនឹងគោលដៅរបស់សាកលវិទ្យាល័យ
- ផ្ទុយនឹងច្បាប់ និង បទបញ្ជា
- ធ្វើផ្ទុយនឹងបែបបទនៃការប្រជុំដែលមានចែងក្នុងមាត្រា ១០ ។

២៥.២-ការលុបចោលឬការផ្អាកទុកទាំងនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ដោយមានបញ្ជាក់ពីមូលហេតុតាមគំនិតផ្ទាល់ខ្លួនឬតាមបណ្តឹងពីភាគីនានាដែលពាក់ព័ន្ធ ។ ការលុបចោលឬការផ្អាកទុកនូវ សេចក្តីសម្រេចនេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់សាកលវិទ្យាធិការ នៃ **ស.ទ.ស.** ហើយសកលវិទ្យាធិការត្រូវជូនពត៌មានបន្តទៅក្រុមប្រឹក្សាភិបាល ក្នុងរយៈពេលដ៏ឆាប់បំផុត ។

**មាត្រា ២៦.-**

រដ្ឋមន្ត្រីក្រសួងសុខាភិបាល អាចចាត់ឱ្យធ្វើអធិការកិច្ច ឬការត្រួតពិនិត្យការងាររបស់សាកលវិទ្យាល័យ ក្នុងករណីដែលយល់ថាជាការចាំបាច់ស្របតាមល័ក្ខខ័ណ្ឌ និង បែបបទ ដែលមានចែងក្នុងច្បាប់ និង បទប្បញ្ញត្តិដែលមានជាធរមាន ។

## ផ្នែកទី២

## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា ២៧ .-**

២៧.១ - ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល សាកលវិទ្យាធិការ នៃ **ស.វ.ស.** ត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំជូនរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។ រដ្ឋមន្ត្រីក្រសួងសុខាភិបាល មានរយៈពេល ១ (មួយ) ខែ គិតចាប់ថ្ងៃទទួលឯកសារ ដើម្បីផ្ដល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃទទួលឯកសារដែលបញ្ជូនមកដោយសាកលវិទ្យាធិការនៃ **ស.វ.ស.**ដើម្បី ផ្ដល់ការយល់ព្រមលើឯកសារទាំងនេះ ។

២៧.២ - លិខិតយល់ព្រមដែលចុះហត្ថលេខាត្រឹមត្រូវ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ អ្នកតំណាង ត្រូវផ្ញើទៅសាកលវិទ្យាធិការនៃ **ស.វ.ស.** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។ សាកលវិទ្យាធិការនៃ **ស.វ.ស.** ត្រូវជូនពត៌មាននេះដល់ក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មិនបានឆ្លើយតបក្នុងរយៈពេលដូចបានកំណត់ខាងលើ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព ។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានយោបល់ជំទាស់លើរបាយការណ៍ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាល ឱ្យបានឆាប់រហ័សបំផុត ដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនេះ ។ របាយការណ៍ ហិរញ្ញវត្ថុប្រចាំឆ្នាំ មិនអាចត្រូវសម្រេចយល់ព្រមបានឡើយ ក្នុងករណីដែលការជំទាស់ ដែលលើកឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុពុំត្រូវបានដោះស្រាយនៅឡើយនោះ ។

**មាត្រា ២៨ .-**

សេចក្តីសម្រេចដូចរៀបរាប់ខាងក្រោមនេះរបស់ក្រុមប្រឹក្សាភិបាល ឬសាកលវិទ្យាធិការ **ស.ទ.ស.** ត្រូវដាក់សុំការអនុញ្ញាតជាមុនពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមការផ្តល់យោបល់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួមមាន :

- សេចក្តីសម្រេចស្តីពីការលក់ ឬ ផ្ទេរសិទ្ធិអចលនទ្រព្យ
- សេចក្តីសម្រេចស្តីពីការលើកលែងឥណទេយ្យ ដែលមានទឹកប្រាក់លើសពីការកំណត់ របស់ប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សេចក្តីសម្រេចស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និង កិច្ចព្រមព្រៀងសម្រាប់ការធានា ឬលិខិតស្រដៀងគ្នានេះ ។

**មាត្រា ២៩ .-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមួយរូបប្រចាំ **ស.ទ.ស.** ។ មន្ត្រីនេះមានភារកិច្ចធ្វើការត្រួតពិនិត្យជាមុននិងជាក្រោយលើ **ស.ទ.ស.** ស្របតាមអនុក្រឹត្យលេខ ៨១ អនក្រ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតឡើងនូវការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាតាមក្រសួង អង្គភាពមូលដ្ឋាន តាមបណ្តាខេត្ត-ក្រុង និងតាមអង្គភាពសាធារណៈដែលមានលក្ខណៈរដ្ឋបាល ។

**មាត្រា ៣០ .-**

៣០.១- ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែ នៃ **ស.ទ.ស.** ស្ថិតនៅក្រោមការត្រួតពិនិត្យ របស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

៣០.២- ការគ្រប់គ្រងរបស់ភ្នាក់ងារគណនេយ្យ ត្រូវស្ថិតក្រោមការត្រួតពិនិត្យ របស់ភ្នាក់ងារគណនេយ្យកណ្តាលនៃរតនាគារជាតិ និង ក្រោមការត្រួតពិនិត្យ របស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ ។

៣០.៣- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់ អធិការកិច្ច ឬ ការត្រួតពិនិត្យលើសាកលវិទ្យាល័យនៅពេលដែលយល់ថា ចាំបាច់ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ពាក់ពន្ធ័ និង បទប្បញ្ញត្តិដែលមានជាធរមាន ។

# ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ៣១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ. ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣២
- ឯកសារ កាលប្បវត្តិ